# សង្ខេបអំពី "កំពង់ផែអូរកែវ"

កំពង់ផែអូរកែវ (បារាំងសរសេរ "Oc-Eo") ស្ថិតនៅតំបន់ដីសណ្ដរទន្លេមេគង្គដែលបច្ចុប្បន្នស្ថិតនៅភាគខាងត្បូងប្រទេសវៀតណាម។ កំពង់ផែអូរកែវជាកំពង់ផែដែលល្បីជាងគេនៅអាស៊ីអាគ្នេយ៍ ចាប់ពីស.វទី១ ដល់ស.វទី៦ (រវាងគ.ស ៥៥០) នៅក្នុងរដ្ឋមួយដែលចិនហៅ "ហ្វុណាន់"(扶南 = Funan)។ ហ្វុណាន់ មានអំណាចនយោបាយខ្លាំង និងមានទឹកដីលាតសន្ធឹងគិតចាប់ពីទឹកដីប្រទេសកម្ពុជាបច្ចុប្បន្ន រហូតដល់ភាគខាងត្បូងនៃប្រទេសវៀតណាមបច្ចុប្បន្ន។

កំពង់ផែអូរកែវ ជាក្រុងពាណិជ្ជកម្មមានសក្ដានុពលខ្លាំងទាក់ទាញអ្នកជំនួញទាំងក្នុងស្រុក និងក្រៅស្រុក។ តាមរយៈនៃការធ្វើកំណាយរបស់បុរាណវិទូជនជាតិរបស់បារាំងលោក ម៉ាល់ឡឺរេ (Malleret, L. *L'archéologie du delta du Mékong II: La civilisation matérielle d'Oc-Eo*, Publ. de École Française d'Extrême-Orient, Paris, 1960) នៅទសវត្ស១៩៤០ បានរកឃើញវត្ថុសិល្បៈជាច្រើន ដែលបង្ហាញថាមានជនជាតិបរទេសច្រើនសាសន៍មកធ្វើជំនួញនៅទីនោះ។ ជនជាតិបរទេសទាំងនោះ ក្រៅពីជនជាតិចិន និងឥណ្ឌាក៏មានជនជាតិដែលរស់នៅម្ដុំជុំវិញសមុទ្រមេឌីទែរ៉ាណេដែរ។ ជាតឹកតាង គេបានរកឃើញកាក់មាសរបស់ចក្រភពរ៉ូមម៉ង់នៅទីនោះ។ ក្រៅពីនេះ គេរកឃើញដូចជាអង្កាំ កាក់ ពុម្ពធ្វើគ្រឿងអលង្ការជាដើម។ល។ សព្វថ្ងៃគេដាក់តាំងវត្ថុសិល្បៈទាំងនោះ នៅក្នុងសារមន្ទីរសិល្បៈហូជីមិញប្រទេសវៀតណាម។

នៅពាក់កណ្ដាលស.វទី៦ (គ.ស ៥៥០) រដ្ឋហ្វុណាន់ធ្លាក់ឬក៏គ្មាននិយាយនៅក្នុងឯកសារចិនទៀតទេ។ តាមឯកសារចិននិយាយថាមានរដ្ឋថ្មី ហើយមានអំណាចខ្លាំងមួយទៀតចាប់ផ្ដើមវាយលុករដ្ឋហ្វុណាន់ និងកាន់កាប់អំណាចទាំងស្រុងនៅពាក់កណ្ដាលស.វទី៦។ រដ្ឋថ្មីនោះចិនហៅ ចេនឡា (真臘 = Zhēnlà) ហើយដែលចិននៅបន្តហៅស្រុកខ្មែរថា "ចេនឡា" រហូតដល់ស.វទី១៣-១៤ (នៅក្នុងកំណត់ត្រារបស់អ្នកការទូតចិន ជីវ តាក្វាន់

អត្ថបទដោយ៖ លោក ញ៉ឹម សុជាវិទ្ធ

ដែលមកស្រុកខ្មែរនៅឆ្នាំ១២៩៦-៩៧ ក៏មាននិយាយអំពីឈ្មោះ ចេនឡា នេះដែរ)។ បញ្ហាមួយទៀតកំពង់ផែអូរកែវដែលធ្លាប់ដំណើរជាង៥០០ឆ្នាំបានបញ្ចប់ នោះដោយសារតែមានចលនាផ្នែកពាណិជ្ជកម្មតាមសមុទ្របានបង្វែរទៅខាងឈូងសមុទ្របេងហ្កាល់។

សព្វថ្ងៃទីកន្លែងដែលលោក ម៉ាល់ឡឺរេ បានធ្វើកំណាយនោះ គេបានសាងជាសារមន្ទីរតូចមួយសម្រាប់អ្នកទេសចរ។ នៅជុំវិញទីតាំងនោះមានតែវាលស្រែ និងមានអូរតូចមួយនៅក្បែរសារមន្ទីរនោះ។ នៅតាមច្រាំងនៃអូរនោះ ឃើញនៅមានអង្កាំលាយឡំនឹងអាចម៍ដី។




សារមន្ទីរអូរកែវ




កាក់មាសរ៉ូម៉ង់

អត្ថបទដោយ៖ លោក ញឹម សុជាទិន្ទ



អង្កាំ



ពុម្ព



កាក់